# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចព្រមព្រៀង
## រវាង
## រោងចក្រ ថប ស៊ីលវើរ លីមីធីត
## ជាមួយតំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ
## រោងចក្រ ថប ស៊ីលវើរ លីមីធីត
## ស្តីអំពីការព្យួរកិច្ចសន្យាការងារ

នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង០៩ និង ០០នាទីព្រឹក នៅក្នុងរោងចក្រ **ថប ស៊ីលវើរ លីមីធីត (ស្វាយអន្ទរ)** មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន តំណាងកម្មករ និយោជិត និងប្រធានក្រុម ។ នៅក្នុងអង្គប្រជុំ នេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាព បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញ ដែល បណ្តាលឱ្យសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករនិយោជិតចំនួន ៦៩៨នាក់ (ស្រី ៦៥៦នាក់ ក្នុងចំណោមចំនួនកម្មករនិយោជិតសរុប ៦៩៨នាក់ រយៈពេល ០២ខែ ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២៤ ។ ហើយក្នុងអំឡុងពេល ព្យួរការងារនេះ កម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូនរបស់ក្រុមហ៊ុន តាមលក្ខខណ្ឌដូចខាងក្រោម៖

- ចំនួន ១៥ដុល្លារអាមេរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ ។
- ចំនួន ៣០ដុល្លារអាមេរិក ពីនិយោជក សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ ។
- ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងាររយៈពេល ៦២ថ្ងៃ កម្មករនិយោជិតទទួលបានប្រាក់ឧបត្ថម្ភពីក្រុមហ៊ុនចំនួន ៦០ដុល្លារអាមេរិក ។
- កាលបរិច្ឆេទបើកប្រាក់ឧបត្ថម្ភព្យួរការងារលើកទី ០១ នៅថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០២៤ លើកទី០២ នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៤ ។

អង្គប្រជុំបានចប់វេលាម៉ោង ១១ និង ០០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសងខាងមានភាព ស្និទ្ធស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

ថ្ងៃពុធ២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ២៥៦៧
ស្វាយអន្ទរ.ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣

**តំណាងក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត TOP SILVER LIMITED KINGDOM OF CAMBODIA

**ស្នាមមេដៃតំណាងកម្មករ និយោជិត**
**កិច្ចព្រមព្រៀង**
**រវាង**
**ក្រុមហ៊ុន ថបស៊ីលវើរលីមីធីត (ស្វាយអន្ទរ)**
**ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន**

Scanned with CamScanner

ថុល ម៉ី    ពន់ នីរដ្ឋ    ខឹម សម្បត្តិ    ឆាត់ ឆារ៉េន

ថន សោភិញ    ដួង សុភឿន

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ថប ស៊ីលវើរ លីមីធីត
TOP SILVER
LIMITED
KINGDOM OF CAMBODIA

Scanned with CamScanner